# សមាគមឆ្មបកម្ពុជា

## សមិទ្ធិផលដែលបានអនុវត្តក្នុងឆ្នាំ២០២៣និង ត្រីមាសទី១ឆ្នាំ២០២៤

លោកស្រី. ឆាយ ស្វែងជាអាទិ៍ ប្រធានសមាគមឆ្មបកម្ពុជា

ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០២៤

# មាតិកា

១.ស្ថានភាពសមាគមឆ្មបកម្ពុជា

២.សកម្មភាពដែលបានធ្វើ

៣.កត្តាប្រឈម

៤.ផែនការបន្ត

# ១.ស្ថានភាពរបស់សមាគមឆ្មបកម្ពុជា

- សមាគមឆ្មបកម្ពុជា ត្រូវបានបង្កើតឡើងដោយមានការចូលរួមពីបុគ្គលិកឆ្មប នៅក្នុងទូទាំងប្រទេស កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ ១៩៩៤ ហើយមានរយៈពេលធ្វើសកម្មភាពមិនកំណត់។
- មានទីតាំងបណ្តោះអាសន្ននៅមជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក
- ជាសមាជិករបស់សហព័ន្ធឆ្មបអន្តរជាតិនៅឆ្នាំ1996
- មាន **33**សាខា ទូទាំងខេត្តក្រុង
- មានសមាជិកចំនួន **5041**នាក់ ឆ្នាំ2022 ប៉ុន្តែ 3500នាក់ឆ្នាំ2024

# ចក្ខុវិស័យ

- ជាស្ថាប័នឈានមុខគេខាងវិជ្ជាជីវៈឆ្មប ដើម្បីបម្រើប្រយោជន៍សាធារណៈ សំដៅជួយកាត់បន្ថយអត្រាមរណៈ និងអត្រាកើតជម្ងឺរបស់មាតា និងទារកទើបកើតនៅក្នុងប្រទេសកម្ពុជា។

# បេសកកម្ម

- ផ្តល់សេវាថែទាំដ៏ល្អ ដោយឆ្មបជំនាញ សម្រាប់ស្ត្រី និងកុមារនៅគ្រប់កម្រិតជាពិសេសក្នុងសហគមន៍
- រៀបចំបង្កើត និងកែលម្អការអនុវត្តន៍វិជ្ជាជីវៈឆ្មប តាមរយៈការផ្តល់សេវា ដែលមាណកុណភាពល្អបំផុតដល់ស្ត្រី គ្រួសារ និងសហគមន៍
- ការពារសិទ្ធិ និងការពង្រឹងតួនាទី និងទំនួលខុសត្រូវរបស់ឆ្មបប្រកបដោយសេចក្តីថ្លៃថ្នូរ គុណភាព ភាពស្មោះត្រង់ និងប្រសិទ្ធភាព។

# គោលដៅរួម

- ដើម្បីលើកកម្ពស់ស្តង់ដានៃការអនុវត្តវិជ្ជាជីវៈឆ្មប ឆ្ពោះទៅកាន់កម្រិតដ៏ខ្ពស់បំផុតមួយ តាមដែលអាចធ្វើទៅបាន។

# គុណតម្លៃ

- គោរពគ្នាទៅវិញទៅមក
- អភិវឌ្ឍន៍ផ្នែកបណ្ដុះបណ្ដាលជាបន្តបន្ទាប់
- សុច្ចរិត និងយុត្តិធម៌
- គណនេយ្យភាព និងការទទួលខុសត្រូវ
- ណែនាំ និងសម្របសម្រួល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ៣៣៦ សណ៍ណ

ថ្ងៃ...ខែ...ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី..០៤..ខែ..កុម្ភៈ..ឆ្នាំ២០២១

**ជម្រាបមក**
**លោកស្រី ខៀវ ម៉ាលី**
**ប្រធានសន្និបាតសមាគមឆ្មបកម្ពុជា**

**កម្មវត្ថុ** ៖ ស្តីពីសំណើសុំទទួលស្គាល់ប្រធាន សមាសភាពថ្មី នៃរចនាសម្ព័ន្ធ ប្តូរលក្ខន្តិកៈ និងប្តូរអាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់សមាគមឆ្មបកម្ពុជា។

**យោង** ៖-ព្រះរាជក្រមលេខ នស/រកម/០៨១៥/០១០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល
-លិខិតលេខ៨២៣ សជណ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០៣ របស់ក្រសួងមហាផ្ទៃ
-លិខិតលេខ០៧/២០ ស.ឆ.ក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ របស់សមាគមឆ្មបកម្ពុជា។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកស្រីប្រធានសន្និបាតសមាគម ថា ក្រសួងមហាផ្ទៃ យល់ព្រមទទួលស្គាល់ប្រធាន សមាសភាពថ្មី នៃរចនាសម្ព័ន្ធ ប្តូរលក្ខន្តិកៈ និងប្តូរអាសយដ្ឋាននៃទីស្នាក់ការកណ្តាលមកតាំងនៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក បន្ទប់អគារសួនសុខភាព ជីឡូត៍៣១A ផ្លូវប្រទេសបារាំង(លេខ៤៧) ក្រុមទី១២៣ ភូមិ៩ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ តាមរយៈកំណត់ហេតុសន្និបាត កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២០។ ចំពោះប្រធាន សមាសភាពថ្មី នៃរចនាសម្ព័ន្ធ មានរាយនាមខាងក្រោម៖

| ល.រ | គោត្តនាម និងនាម | តួនាទី | សេចក្តីផ្សេងៗ |
|---|---|---|---|
| ១ | លោកស្រី ឆាយ ស្វែងជាអាទិ៍ | ប្រធានសមាគម | |
| ២ | លោកស្រី ហេង ធីម | អនុប្រធានទទួលបន្ទុកអប់រំបណ្តុះបណ្តាល | |
| ៣ | កញ្ញា ឈិន សុខណាយ | អនុប្រធានទទួលបន្ទុករដ្ឋបាល/ហេរញ្ញិក | |

ទន្ទឹមនេះ សមាគមឆ្មបកម្ពុជា ត្រូវធ្វើសកម្មភាពស្របតាមច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដូចបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ។

អាស្រ័យហេតុនេះ សូមលោកស្រីប្រធានជ្រាបជាព័ត៌មាន និងជាតម្រូវអនុវត្តតាមការគួរ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

ប៊ុន ហ៊ុន

**ចម្លងជូន ៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
  "ដើម្បីជូនជ្រាប"
- សាលារាជធានីភ្នំពេញ
  "ដើម្បីមុខការ"
- ឯកសារ - កាលប្បវត្តិ

# អង្គការលេខសមាគមឆ្មបកម្ពុជា



# WEBSITE:

https://cmamidwives.wixsite.com/-cma

face Book



# ២.សកម្មភាពដែលបានធ្វើ

1. ប្រារព្ធទិវាឆ្មបឆ្នាំ២០២៣
2. ចុះពង្រឹងការងារនៅតាមខេត្តបានចំនួន១០លើក
3. ធ្វើសិក្ខាសាលាស្តីពីការគាំទ្របច្ចេកទេសដល់ឆ្មបថ្មីទើបចប់បានចំនួន២លើក ឧបត្ថម្ភថវិការដោយ UNFPA
4. សហការជាមួយសមាគមឆ្មបប្រទេសបារាំងធ្វើការបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការថែទាំប៉េរីណេដើម្បីកាត់បន្ថយការស្រុតស្បូនពេលឈឺពោះសម្រាលកូនបាន១លើក

# ២.សកម្មភាពដែលបានធ្វើ(ត)

5. ធ្វើសិក្ខាសាលាបូកសរុបលទ្ធផលប្រចាំឆ្នាំរបស់សមាគមឆ្មប

6. បណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ឆ្មបនៅតាមសាខាដើម្បីបង្កើនធនធានគ្រូបង្គោលតាមសាខា។

7. ជាសមាជិកក្រុមការងារលើកកំពស់គុណភាពព្យាបាលនិងថែទាំ សុខភាពមាតានិងទារក ដែលចូលប្រជុំជាទៀងទាត់។

8. ចូលរួមសន្និបាតប្រចាំឆ្នាំរបស់ក្រសួងសុខាភិបាល

# ទិវាឆ្មបឆ្នាំ២០២៣









# ចុះពង្រឹងការងារនៅតាមខេត្ត















# សិក្ខាសាលាស្តីពីការគាំទ្របច្ចេកទេសដល់ឆ្មបថ្មីទើបចប់សិក្ខា សាលាស្តីពីការគាំទ្របច្ចេកទេសដល់ឆ្មបថ្មីទើបចប់











# សកម្មភាពរៀនគ្រូបង្គោល










Pelvic Floor Reeducation During Perinatal Period









# សន្និបាតបូកសរុបរបស់សមាគមឆ្មបកម្ពុជា








# កត្តាប្រឈម

១. ផ្ទុបចូលជាសមាជិកសមាគមនៅមានកំរិត

២. ប្រធានសាខាតាមខេត្តមួយចំនួនមិនសូវសកម្មការងាររបស់សមាគម។

៣.ពេលចូលនិវត្តគាត់ឈប់ចូលរួមគ្រប់គ្រងសមាជិកធ្វើឱ្យបាត់បង់សមាជិក។

៤. សមាគមមិនទាន់មានទីតាំងផ្ទាល់ខ្លួន។

# ផែនការបន្ត

១. គ្រប់គ្រងWebsite និងផ្សព្វផ្សាយដល់សមាជិកឱ្យប្រើប្រាស់

២. បន្តការបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ និង ផ្ទាល់

៣. ផ្សព្វផ្សាយ link E-learning ដល់សមាជិកអោយចូលរៀនយកពិន្ទុ

៤. បោះឆ្នោតជ្រើសរើសប្រធានសាខាថ្មីដែលផុតអណត្តិ

៥. បង្កើនទំនាក់ទំនង និងសហការជាមួយដៃគូអភិវឌ្ឍនានាដើម្បីគាំទ្រដល់ការងារឆ្មបក្នុងគោលបំណងផ្តល់សេវាប្រកបដោយ គុណភាព។

# Link E-Learning

https://
elearning.nmchc.gov.kh/
9:52 AM

# សូមថ្លែងអំណរគុណ

- ក្រសួងសុខាភិបាលដែលមានការគាំទ្រពេញទំហឹង
- មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកមានការគាំទ្រពេញទំហឹង
- អង្គការដៃគូផ្សេងៗ៖UNFPA, WHO, A &T, FHI 360, HACC,RHAC,MSI,PSI,ឧបត្ថម្ភកម្មវិធីថ្ងៃនេះ
- អង្គការ UNICEF ឧបត្ថម្ភ Zoom Link កញ្ចប់ធំ ៥OOនាក់ ក្នុងឆ្នាំ២០២៤នេះ។

# សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់

